ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៣ លេខ ១១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

# Work Activities

ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០១០



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី របបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះនៅសហគមន៍ | ១-២ |
| ២- | សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១១-២០១៣ | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃនាមដូនសំលើផ្ទៃដីទំហំ ១៥០០ហិកតា ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ | ៤ |
| ៤- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ | ៥ |
| ៥- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរនៅតាមការផ្សព្វផ្សាយសាធារណៈ | ៦ |
| ៦- | កិច្ចប្រជុំឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម | ៧ |
| ៧- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១០ | ៨ - ១១ |
| ៨- | សកម្មភាពដ៏ទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ - ១៦ |
| ៩- | ដំណើរទស្សនកិច្ចពិភាក្សា (Retreat) ស្តីពីការរៀបចំការងារ ដើម្បីត្រៀមអនុវត្តគម្រោងវាយតម្លៃ ផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត | ១៧ |

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# របបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះនៅសហគមន៍

កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្ដម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្ដម **លឹម អេខ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពី **របបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះនៅសហគមន៍** ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក និង អគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសេចក្ដីអនុក្រឹត្យស្ដីពី របបគោលនយោបាយចំពោះជនពិការ ដោយអនុលោមតាម៖

-អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសប្រារព្ធទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការជំរុញការរៀបចំលិខិតបទដ្ឋាន និងយន្តការសម្រាប់អនុវត្តច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងសារលិខិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាអន្តរជាតិស្ដីពី គ្រួសារ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១០។

-កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ចតុកោណទី៣ មុំទី៤ ដែលចែងថា៖ រាជរដ្ឋាភិបាលនឹងបង្កើនអន្តរាគមន៍ក្នុង



វិស័យសង្គមកិច្ច នៅក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ បង្កើនសកម្មភាពសង្គ្រោះបន្ទាន់ ដើម្បីជួយដល់អ្នករងគ្រោះដោយធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ និងពង្រីកកម្មវិធីស្ដារលទ្ធភាពពលកម្មសម្រាប់ជនពិការ ព្រមទាំងកម្មវិធីលើកកម្ពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រាស្ដ្រីរងគ្រោះ ជនអនាថាដែលគ្មានទីពឹង អតីតយុទ្ធជន និងគ្រួសារ។

-ច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ មាត្រា១២ ចែងថា៖ រដ្ឋត្រូវរៀបចំគោលនយោបាយ ផ្គត់ផ្គង់ និងមានថវិកាប្រចាំឆ្នាំ ដើម្បីជួយឧបត្ថម្ភដល់ជនពិការដែលមានកម្រិតពិការភាពធ្ងន់ធ្ងរ និងក្រីក្របំផុតនិងគ្មានទីពឹង ឬចាស់ជរានិងក្រីក្របំផុតគ្មានទីពឹង ឬមានគ្រោះថ្នាក់ធ្ងន់ធ្ងរនិងក្រីក្របំផុតគ្មានទីពឹង។ រដ្ឋត្រូវមានថវិកាប្រចាំឆ្នាំ ដើម្បីធ្វើសមាហរណកម្មជនពិការទៅក្នុងសហគមន៍។ មាត្រា១៩ ចែងថា៖ គោលនយោបាយជួយឧបត្ថម្ភសេវាពិនិត្យ ថែទាំសុខភាព ព្យាបាល និងស្ដារលទ្ធភាពពលកម្មកាយសម្បទា ដល់ជនពិការដែលមានពិការភាពធ្ងន់ធ្ងរ ឬក្រីក្របំផុតគ្មានទីពឹង ត្រូវកំណត់ដោយអនុក្រឹត្យ។

សេចក្តីព្រាងអនុក្រឹត្យមានសារៈសំខាន់ដូចខាងក្រោមនេះ៖

- លើកកម្ពស់សុខុមាលភាព ជីវភាពរស់នៅ និងការពារជនពិការ និងជនក្រីក្រងាយរងគ្រោះនៅតាមសហគមន៍
- បង្កើតសំណាញ់សុវត្ថិភាពសង្គម ដើម្បីទប់ស្កាត់ភាពងាយរងគ្រោះរបស់ប្រជាជននៅតាមសហគមន៍
- បង្កើនសេវាសង្គមកិច្ចតាមសហគមន៍ រួមចំណែកទប់ស្កាត់ទុរគតភាព ការហូរចូលជនអនាថាមកកាន់ទីក្រុង និងទីប្រជុំជន កាត់បន្ថយជាបណ្តើរៗការផ្តល់សេវាជូនជនរងគ្រោះតាមមជ្ឈមណ្ឌលរដ្ឋ
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងការបែងចែកផ្លែផ្កានៃការអភិវឌ្ឍ ប្រកបដោយសមធម៌
- ពង្រឹងពង្រីកតួនាទីរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សេវាសង្គមកិច្ច ជូនប្រជាជនក្រីក្រងាយរងគ្រោះ និងលើកកម្ពស់សុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជាជនក្រីក្រងាយរងគ្រោះ
- បង្កើនភាពជាដៃគូ ជាមួយកាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងការអភិវឌ្ឍសេវាសង្គមកិច្ចសម្រាប់ប្រជាជនទូទៅ(១)។




អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យនេះយ៉ាងយកចិត្តទុកដាក់ ហើយបានស្នើឱ្យតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានអញ្ជើញចូលរួមប្រជុំ យកសេចក្តីព្រាងអនុក្រឹត្យនេះដាក់ឆ្លងឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិចារណាខ្លឹមសារឡើងវិញ ជាមួយនឹងជម្រើសពីរដែលអង្គប្រជុំបានលើកឡើងដូចខាងក្រោមនេះ៖

**ជម្រើសទី១៖** មាត្រា១២ គ្របដណ្តប់ជនពិការទាំងនៅក្នុងមជ្ឈមណ្ឌល និងទាំងនៅក្នុងសហគមន៍។ អនុក្រឹត្យនេះត្រូវនិយាយតែជនពិការដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

**ជម្រើសទី២៖** ឱ្យនិយមន័យជនពិការ និងជនក្រីក្រងាយរងគ្រោះឱ្យបានច្បាស់លាស់ និងពង្រួម វិសាលភាពនៃជនក្រីក្រងាយរងគ្រោះឱ្យមានទំហំតូច ដែលសេវាសង្គមកិច្ចយល់ឃើញថាចាំបាច់។

អង្គប្រជុំជំនាញបច្ចេកទេស បានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះជាបណ្តោះអាសន្នសិន៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការ និងជនក្រីក្រងាយរងគ្រោះនៅសហគមន៍។

# សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១១ - ២០១៣

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡែន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុក ឆវិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១១-២០១៣** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងផែនការ សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



ដោយផ្អែកលើស្មារតីនិងខ្លឹមសារនៃ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ កម្មវិធីវិយោគសាធារណៈបីឆ្នាំរំកិល (ក.វ.ស.) លើកនេះ ត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់កត្តាចម្បង និងស្ថានភាពជាក់ស្តែងបីសំខាន់ៗពោលគឺ ទី១ ការបង្ហាញពីទិន្នន័យគម្រោងវិនិយោគ ដែលមានអាទិភាពខ្ពស់របស់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយ មានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និងជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តគោលគោលនយោបាយ ដែលមានចែងនៅក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ ទី២ តម្រូវការចំណាយសរុបសម្រាប់អនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ (ប្រមាណជិត ៦៣០០ លានដុល្លារអាមេរិក) និងទី៣ បរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលបាន សន្យានៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា វ.ស.អ.ក. លើកទី៣ នាខែមិថុនា ឆ្នាំ២០១០ កន្លងទៅនេះ (ប្រមាណជិត មួយពាន់លានដុល្លារអាមេរិក)។

ក.វ.ស. បីឆ្នាំរំកិល ២០១១-២០១៣ ដែលមានតម្លៃសរុបប្រចាំឆ្នាំប្រមាណ ១៤០០ លានដុល្លារអាមេរិក ត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការចំណាយសម្រាប់អនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ (៦៣០០ លានដុល្លារអាមេរិក) ដើម្បីឱ្យបានស្របតាមស្ថានភាពជាក់ស្តែងនៃការប្រែប្រួលថ្លៃទំនិញ និងអតិផរណា ហើយក៏ផ្អែកលើបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការដែលដៃគូអភិវឌ្ឍបានពន្យានៅក្នុង វ.ស.អ.ក. លើកទី៣ នាខែមិថុនា ឆ្នាំ២០១០ កន្លងទៅនេះ (ប្រមាណជិតមួយពាន់លានដុល្លារអាមេរិក) ផងដែរ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងអនុក្រឹត្យនេះយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលពាក្យពេចន៍ ឃ្លាប្រយោគ និងស្នើឱ្យក្រសួងសរសេរតួលេខឱ្យបានរលូនឡើងវិញ។ អង្គប្រជុំក៏បានកត់សម្គាល់ថាឯកសារកម្មវិធីវិនិយោគសាធារណៈឆ្នាំមុនៗ មានជំពូកចែងពី "តាមដាន និងវាយតម្លៃ" ប៉ុន្តែសម្រាប់ឯកសារឆ្នាំនេះ ជំពូកនេះមិនមានចែងទេ គឺទុកឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកទទួលបន្ទុកការងារនេះវិញ។ ដូចនេះ ក្រសួងផែនការមិនបានបញ្ចូលជំពូកនេះទេ តែបានរំលេចនៅក្នុងសេចក្តីផ្តើម ក្នុងកថាខណ្ឌទី១៣។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១១-២០១៣។

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ លើផ្ទៃដីទំហំ ១៥០០ហិកតា ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ

កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្ដម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្ដម **អៀម សារ៉េត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំលើផ្ទៃដីទំហំ ១៥០០ហិកតា ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងបរិស្ថាន សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។



ក្រសួងបរិស្ថានបានរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វ ព្រៃរនាមដូនសំលើផ្ទៃដីទំហំ ១៥០០ហិកតា ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ដើម្បីឱ្យស្របតាមច្បាប់ស្ដីពី តំបន់ការពារធម្មជាតិ សម្រាប់ឱ្យប្រជាពលរដ្ឋមានសិទ្ធិបង្កបង្កើនផល និងប្រើប្រាស់ដីធ្លីដោយស្របច្បាប់។

ដែនជម្រកសត្វព្រៃរនាមដូនសំ គឺជាតំបន់ការពារធម្មជាតិមួយក្នុងចំណោមតំបន់ការពារធម្មជាតិទាំង២៣ ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន។ យោងតាមព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ដែនជម្រកសត្វព្រៃរនាមដូនសំ មានផ្ទៃដីសរុបចំនួន ១៧៨,៧៥០ហិកតា និងគ្របដណ្ដប់លើខេត្តចំនួន៣គឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបូង និងខេត្តប៉ៃលិន ក៏ប៉ុន្តែនៅឆ្នាំ២០០៣ ដែនជម្រករនាមដូនសំ ត្រូវបានកែសម្រួលផ្ទៃដីពីទំហំ ១៧៨,៧៥០ហិកតា មកត្រឹម ៤០,០២១ហិកតា តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣(១) ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្ដីព្រាងនេះ កាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះទាំងស្រុង ៕

---

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុស្ដីពី សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំលើផ្ទៃដីទំហំ ១៥០០ហិកតា ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងទេសចរណ៍ សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងទេសចរណ៍បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ក្នុងគោលបំណងសំខាន់ពីរគឺ ១-អនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលផ្តោតជាសំខាន់លើការពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍រវាងប្រទេសសមាជិកអាស៊ាន ពិសេសដើម្បីជួយគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍធនធានមនុស្ស ២-ចូលរួមអនុវត្តស្មារតីនៃផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ាន (ATSP ២០១១-២០១៥ ) ដែលរំពឹងថា នឹងត្រូវអនុម័តដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ានក្នុងឱកាសទិវាទេសចរណ៍អាស៊ាន (ATF-2011) នៅរាជធានីភ្នំពេញ នាខែមករា ឆ្នាំ២០១១ ខាងមុខនេះ ដោយសំដៅធ្វើយ៉ាងណាឱ្យអាស៊ានជាគោលដៅទេសចរណ៍លំដាប់ពិភពលោក (ASEAN-A World Class Tourist Destination) និងផ្តល់ភាពកក់ក្តៅដល់ទេសចរ ( ASEAN-Feel the Warmth) ដែលក្នុងនោះការបង្កើនគុណភាពធនធានមនុស្សក្នុងវិស័យទេសចរណ៍ ដែលជាគោលដៅយុទ្ធសាស្ត្រអាទិភាពមួយ(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងនេះដោយរលូនដោយពុំមានការកែសម្រួលអ្វីជាដុំកំភួនឡើយ លើកលែងតែពាក្យពេចន៍ ឃ្លាប្រយោគតែប៉ុណ្ណោះ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះទាំងស្រុង៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការប្រើប្រាស់ភាសា និងអក្សរខ្មែរ នៅតាមការផ្សព្វផ្សាយសាធារណៈ

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គ ប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គីម សយសាម៉ាឡៃន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **លឹម អេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរ នៅតាមការផ្សព្វផ្សាយសាធារណៈ** ដោយមានការអញ្ជើញចូលរួមពី តំណាងគណៈកម្មាធិការជាតិភាសាខ្មែរ សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

គណៈកម្មាធិការជាតិភាសាខ្មែរ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរ នៅតាមការផ្សព្វផ្សាយសាធារណៈ ដែលមានគោលបំណងដូចខាងក្រោម៖

- លើកកម្ពស់ភាសានិងអក្សរខ្មែរ
- រក្សាឱ្យបាននូវអត្តសញ្ញាណដ៏ថ្លៃថ្នូរនៃជាតិខ្មែរ
- ការឯកភាពក្នុងការសរសេរពាក្យ
- ពិនិត្យនិងកែតម្រូវលើការប្រើប្រាស់ភាសានិងអក្សរខ្មែរ នៅតាមការផ្សព្វផ្សាយសាធារណៈ
- កំណត់គោលការណ៍នៃការសរសេរភាសា និងអក្សរខ្មែរនៅលើស្លាកសញ្ញា ដែលមានអក្សរ បរទេស នៅលាយជាមួយ(១)។



អង្គប្រជុំជំនាញបច្ចេកទេស បានពិនិត្យពិភាក្សាគ្នាលើសេចក្តីព្រាងនេះ ហើយបានសម្គាល់ថា បច្ចុប្បន្ននេះ គណៈកម្មាធិការជាតិភាសាខ្មែរពុំមានសមត្ថភាព និងធនធានមនុស្សគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចបានតាមសេចក្តីព្រាងអនុក្រឹត្យនេះទេ ព្រោះមានវិសាលភាពធំធេង ប៉ុន្តែខ្លឹមសារសម្រាប់ការអនុវត្តជាក់ស្តែង គឺអនុវត្តតែលើស្លាកសញ្ញាប៉ុណ្ណោះ។ បន្ថែមលើនេះទៀត ខ្លឹមសារមាត្រា៩ នៃសេចក្តីព្រាងនេះ បានចែងថា អនុញ្ញាតឱ្យ ក.ជ.ភ.ខ. មានសមត្ថកិច្ចផាកពិន័យលើក្រសួងស្ថាប័នរដ្ឋដ៏ទៃទៀត ដែលកំពុងគ្រប់គ្រងការងារនេះ។ អង្គប្រជុំជំនាញបច្ចេកទេស បានសម្រេចឱ្យស្ថាប័នសាមីកែសម្រួលសេចក្តីព្រាងនេះឡើងវិញ ដោយបង្រួមសមត្ថកិច្ចរបស់ខ្លួនឱ្យនៅត្រឹមតែត្រួតពិនិត្យការប្រើប្រាស់ភាសានិងអក្សរខ្មែរលើស្លាកសញ្ញាផ្សេងៗ។

អង្គប្រជុំជំនាញបច្ចេកទេស បានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះជាបណ្តោះអាសន្នសិន៕

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរនៅតាមការផ្សព្វផ្សាយសាធារណៈ។

## កិច្ចប្រជុំឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពី

# កិច្ចសន្យាពាណិជ្ជកម្ម

កាលពីថ្ងៃទី២ និងទី១៧ និងទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង លោកជំទាវ **លី ឌួចឡេង** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងពាណិជ្ជកម្ម សមាជិក និងអគ្គលេខាធិការរង នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការ គណៈរដ្ឋមន្ត្រី។







អង្គប្រជុំជំនាញបច្ចេកទេសបានបន្តពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះចាប់ពីមាត្រា៥៧។ ការពិនិត្យ និងការពិភាក្សាបានប្រព្រឹត្តទៅដោយប្រុងប្រយ័ត្ន ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាឃ្លោង ដើម្បីឱ្យអ្នកអានយល់បាននូវខ្លឹមសារនៃមាត្រានីមួយៗ ជៀសវាងការបកស្រាយផ្សេង។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅមាត្រា៨៥៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១០

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) បានរៀបចំកិច្ចប្រជុំទូលាយមួយ ក្រោមអធិបតីភាពឯកឧត្ដម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែតុលា ឆ្នាំ២០១០** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។



## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➤ *សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងខែតុលាឆ្នាំ២០១០នេះបន្ត កើនឡើង ១.៤% ទៀត បើធៀបនឹងខែកញ្ញា និងកើនឡើង ៣.៦% ក្នុងរយៈពេល ១២ខែ។* ក្នុងនោះក្រុមម្ហូបអាហាររួមចំណែក ៦៤% ទៅលើការកើនឡើងនៃសន្ទស្សន៍ថ្លៃសរុបនាខែនេះ និងក្រៅពីនោះ ក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀតរួមចំណែក ១៥% ការដឹកជញ្ជូន ៧% និងភោជនីយដ្ឋាន ២%។

➤ *កំណើនសន្ទស្សន៍ថ្លៃក្នុងខែតុលានេះ ធ្វើឲ្យសន្ទស្សន៍ថ្លៃមធ្យមនៃទំនិញប្រើប្រាស់គ្រប់មុខ កើនឡើង ៤.២% បើប្រៀបធៀបរយៈពេល ១០ ខែដូចគ្នា ឆ្នាំ ២០១០/២០០៩។*

➤ បើពិនិត្យតាមក្រុមទំនិញវិញ ការប្រៀបធៀបខែ (តុលា/កញ្ញា) បង្ហាញបំរែបំរួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ក្រុមដែលមានសន្ទស្សន៍ថ្លៃកើនឡើង (ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) | ក្រុមដែលមានសន្ទស្សន៍ថ្លៃថយចុះ (ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| ▪ ម្ហូបអាហារៈ +២% (+៤.៧% )<br>▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀតៈ +១.២% (+៣.៦%)<br>▪ ការដឹកជញ្ជូនៈ +០.៨% (+៣.៨%)<br>▪ ភោជនីយដ្ឋានៈ +០.៥% (+២.៥%)<br>▪ ទំនិញ និងសេវាកម្មផ្សេងទៀតៈ +២.៩% (+១១%) | ▪ ការកំសាន្ត និងវប្បធម៌ៈ –០.៥% (–០.៥%) |

តារាងខាងក្រោម បង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងអំឡុង ៣ឆ្នាំចុងក្រោយ។ និន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃក្នុងឆមាសទី២ ឆ្នាំ២០១០នេះ បន្តកើនឡើង និងមានលក្ខណៈប្លែកពីឆ្នាំមុនៗ។

| ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១០ | ០.០% | ០.៣% | ០.៦% | -០.៣% | ០.២% | ០.០% | ០.៥% | ០.៩% | ០.៧% | ១.៤% | – | – | – |
| ២០០៩ | -១.៥% | -០.១% | ១.៣% | ១.០% | ១.០% | ១.៩% | ១.៤% | ០.៧% | ០.៥% | -០.៣% | -០.៦% | -០.១% | -០.៧% |
| ២០០៨ | ១.៨% | -០.៥% | ៨.៣% | ៤.៤% | ២.៩% | ០.៩% | ០.៥% | -០.៣% | -០.១% | -១.១% | -៣.៤% | -៣.៩% | ២៥% |

➢ ក្នុងខែតុលាឆ្នាំ២០១០នេះ អត្រាប្តូរប្រាក់ **៛/ដុល្លារស្មើនឹង ៤,២២២៛/១ដុល្លារ** បើធៀបនឹងខែមុន ប្រាក់រៀល ឡើងថ្លៃ 0.១% ធៀបនឹងដុល្លារ ប៉ុន្តែចុះថោក ១.២% ក្នុងរយៈពេល១២ខែ ។

➢ អត្រាប្តូរប្រាក់ **៛/បាតស្មើនឹង ១៤១៛/១បាត** បើធៀបនឹងខែមុន ប្រាក់រៀលចុះថោក ១.៤% ធៀបនឹងបាត និងចុះថោក ១៣% ក្នុងរយៈពេល១២ខែ។

➢ អត្រាប្តូរប្រាក់ **៛/ដុង ស្មើនឹង 0.២១៧៛/១ដុង** បើធៀបនឹងខែមុន អត្រានេះស្ថិតនៅស្ថិរ ប៉ុន្តែប្រាក់រៀលឡើងថ្លៃ ៧.៣% ធៀបនឹងដុង ក្នុងរយៈពេល១២ខែ។

## ២) ស្ថានភាពថវិកាជាតិ

➢ *យោងតាមស្ថិតិដែលឆ្លងកាត់តែធនាគារជាតិ **ចំណូលថវិកាជាតិ**ក្នុងខែតុលាឆ្នាំ២០១០នេះ **អនុវត្តបាន**ចំនួន **៤២៨.៦ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៧១% នៃគម្រោង) ក្នុងនោះ **ចំណូលមូលធន ១៧.៣ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ១០% នៃគម្រោង) និង**ចំណូលចរន្ត ៤១១.៣ ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៩៧% នៃគម្រោង)* ។

➢ *បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ**ខែតុលា ថយចុះ៤.៨% និង ថយចុះ0.៧% ក្នុងរយៈពេល១២ខែ ។ **ការថយចុះចំណូលថវិកាជាតិ***នាខែនេះ ជាចំបងបណ្តាលមកពីចំណូលចរន្ត*ថយចុះ៨.២%* ។

- ក្នុងចំណូលចរន្តនាខែតុលា ចំណូលសារពើពន្ធ*ថយចុះ១៦%*ប៉ុន្តែចំណូលមិនមែនសារពើពន្ធកើនឡើង ៥១%។

| ក្នុងចំណូលសារពើពន្ធ | ក្នុងចំណូលមិនមែនសារពើពន្ធ |
|---|---|
| ✓ ពន្ធ និងអាករគយ*ថយចុះ ៣.៧%* | ✓ នេសាទ កើនឡើង ១១0% |
| ✓ ចំណូលពន្ធដារ*ថយចុះ ១៥%* | ✓ រុក្ខាប្រមាញ់ថយចុះ ២៦% |
| ✓ ចំណូលសារពើពន្ធផ្សេងៗកើនឡើង ៦៩% | ✓សម្បទានរ៉ែ ថយចុះ ៧៦% |
| | ✓ អាកាសចរណ៍ស៊ីវិលថយចុះ ២២% |
| | ✓ ផលទុនទេសចរណ៍ ថយចុះ ៥១% |
| | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ កើនឡើង ១៥% |
| | ✓ អាករស្ថានទូត ថយចុះ ១៤% |
| | ✓ ការត្រួតពិនិត្យគុណភាពផលិតផល ថយចុះ ៣.៩% |
| | ✓ ជួលរោងចក្រ សហគ្រាសកើនឡើង ៧0% |
| | ✓ ឯកជនភាវូបនីយកម្ម កើនឡើង ៣៣៥% |
| | ✓ ការលក់អចលនកម្ម កើនឡើង ១៧៧% |

➢ ***ចំណាយថវិកាជាតិ*** នៅខែតុលា ឆ្នាំ២០១០នេះ អនុវត្តបាន **៣៥៦.៩ពាន់លានរៀល** (ជាមធ្យមប្រចាំខែ ស្មើនឹង ៧៤%នៃគម្រោង) ក្នុងនោះ **ចំណាយចរន្ត ២៦0.២ពាន់លានរៀល** (ជាមធ្យមប្រចាំខែ: ៩៦%នៃគម្រោង) និង**ចំណាយមូលធន ៩៦.៧ពាន់លានរៀល** (ជាមធ្យមប្រចាំខែ: ៤0%នៃគម្រោង)។

➢ *បើធៀបនឹងខែមុន **ចំណាយថវិកាជាតិ**ថយចុះ ៤៧% និងថយចុះ ២៥% ក្នុងរយៈពេល១២ខែ* ។ការថយចុះចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្ត*ថយចុះ៥១%* និងចំណាយមូលធន*ថយចុះ៣៣%* ។

➢ ***តុល្យភាពថវិកាជាតិក្នុងខែតុលានេះមានអតិរេកចំនួន ៧១៧.ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុ

➢ ក្នុងខែតុលាឆ្នាំ ២០១០ **រូបិយវត្ថុ** $M_2$ មានចំនួន ***១៩,៣៥៩ពាន់លានរៀល*** កើនឡើង២.៥% ធៀបនឹងខែមុន និងកើនឡើង ២៦% ក្នុងរយៈពេល១២ខែ។ ការកើនឡើងនៃ $M_2$ នាខែនេះបណ្តាលមកពីការកើនឡើងនូវ ប្រាក់បញ្ញើចរន្ត 0.៦% និងប្រាក់បញ្ញើជារូបិយបណ្ណ ៣.៣%។ គួរចាប់អារម្មណ៍ថាមានការថយចុះនៃរូបិយវត្ថុក្រៅធនាគារ 0.៧% *និង*ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ៥.៣% ។

➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** នាខែតុលាឆ្នាំ ២០១០នេះ មានចំនួន**២,៤២២ លានដុល្លារ** ថយចុះ៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៩.៥% ក្នុងរយៈពេល១២ខែ។

➢ ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលក្នុងខែតុលាឆ្នាំ ២០១០ មានចំនួន **២,២១0ពាន់លានរៀល** ក្នុងនោះ ឥណទេយ្យចំពោះរាជរដ្ឋាភិបាល **២៧0ពាន់លានរៀល** និងប្រាក់បញ្ញើរាជរដ្ឋាភិបាល **២,៤៨0 ពាន់លានរៀល**។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែតុលាឆ្នាំ ២០១០នេះ មានចំនួន **៧,៣៨៤ ពាន់លានរៀល** *ថយចុះ ២.៦%* បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៣% ក្នុងរយៈពេល ១២ខែ។

➢ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជមានការកើនឡើងប្រចាំ*** ឯក្នុងខែតុលានេះមានចំនួន ១២,៧០៤ ពាន់លានរៀល កើនឡើង ២.១% បើធៀបនឹងខែមុន និងកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។

➢ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** : ខែនេះមិនទទួលបានទិន្នន័យ។

➢ អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យមនៃធនាគារពាណិជ្ជទាំងអស់) ក្នុងខែតុលានេះស្មើនឹង ៦.៥៩% កើនឡើង 0.៣% ធៀបនឹងខែមុន ប៉ុន្តែថយចុះ 0.៥% ក្នុង រយៈពេល១២ខែ។

➢ អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជ (អត្រាមធ្យម) ស្មើនឹង **៤.៣៩%** ថយចុះ៣.៧% ធៀបនឹងខែមុន និងថយចុះ ២២% ក្នុងរយៈពេល១២ខែ។

➢ អត្រាការប្រាក់កំចីប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យម) ស្មើនឹង ២២.៨១% កើនឡើង 0.១% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១.១% ក្នុងរយៈពេល១២ខែ។

➢ អត្រាការប្រាក់កំចីប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជ (អត្រាមធ្យម) ស្មើនឹង ១៦.១១% ថយចុះ 0.៦% ធៀបនឹងខែមុន និងថយចុះ ១.៥% ក្នុងរយៈពេល១២ខែ។

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢ **កសិកម្ម**

▪ ផលិតកម្មនេសាទ : ខែនេះមិនទទួលបានទិន្នន័យ។

➢ **ឧស្សាហកម្ម**

▪ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ១,១០៥ពាន់លានរៀល (បានពី២០៧រោងចក្រ)។

▪ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៨៣លានគីឡូវ៉ាត់ម៉ោង ថយចុះ ៥.២% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៥% ក្នុងរយៈពេល១២ខែ។

➢ **សំណង់**

▪ **សំណង់អនុញ្ញាតឲ្យសាងសង់**មានចំនួន ១៨៤.១ពាន់ម$^2$ ថយចុះ ៧៥% បើធៀបនឹងខែមុន និង ថយចុះ ៧១% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ៤៧.៨លានដុល្លារ ថយចុះ ៣.៨% បើធៀបនឹងខែមុន និងថយចុះ ៧៨% ក្នុងរយៈពេល ១២ខែ។

▪ **សំណង់ដែលពេញនិយមជាងគេ** យោងតាមតួលេខអនុញ្ញាតនាខែនេះគឺ **លំនៅឋាន** (៨០%នៃសំណង់អនុញ្ញាតសរុប) និងផ្សេងៗ (១២%នៃសំណង់អនុញ្ញាតសរុប) ។

➢ **វិនិយោគ:** គម្រោងវិនិយោគអនុញ្ញាតិដោយ គ.វ.ក.: ខែនេះមិនទទួលបានទិន្នន័យ។

➢ **សេវាកម្ម និងទេសចរណ៍**

▪ **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម**នៅក្រសួងពាណិជ្ជកម្ម មានចំនួន ២៦៧ ថយចុះ ៩.៥% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤១%រយៈពេល ១២ខែ។

▪ **ក្រុមហ៊ុនដែលបានចុះបង់ពន្ធដារតាមរបបពិត** មានចំនួន ១៩៨ ថយចុះ ២.៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២២% ក្នុងរយៈពេល១២ខែ។

▪ **ការដាក់ពាក្យរកការងារទៅក្រៅប្រទេសនៅក្រសួងការងារ**:ខែនេះមិនទទួលបានទិន្នន័យ។

▪ **ទំនិញឆ្លងកាត់តាមផែ** (សរុប៦ផែ) មានចំនួន ៣១៧.៧ ពាន់តោន កើនឡើង ២៨% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ៦.៣% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ

– ទំនិញឆ្លងកាត់ផែកំពង់សោមកើនឡើង ១០% ធៀបនឹងខែមុន និងកើនឡើង ២១% ក្នុងរយៈពេល១២ខែ

– ទំនិញឆ្លងកាត់ផែឧកញ៉ាម៉ុងកើនឡើង ១៦% បើធៀបនឹងខែមុន និងកើនឡើង ១៥0% ក្នុងរយៈពេល១២ខែ

– ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុងថយចុះ ៦៩% បើធៀបនឹងខែមុន និងថយចុះ ៩២% ក្នុងរយៈពេល១២ខែ

–ទំនិញឆ្លងកាត់ផែភ្នំពេញកើនឡើង ១២៨% បើធៀបនឹងខែមុននិងកើនឡើង ២១% ក្នុងរយៈពេល១២ខែ

▪ **អ្នកដំណើរតាមផ្លូវអាកាស** (អន្តរជាតិ) មានចំនួន ២៥១ពាន់នាក់ កើនឡើង ២២% បើធៀបនឹងខែមុន និងកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។

▪ **ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស:** ខែនេះមិនទទួលបានទិន្នន័យ។

▪ **ចំនួនអ្នកទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា**:ខែនេះមិនទទួលបានទិន្នន័យ។

- ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ (ទូទាំងប្រទេស) មានចំនួន៤,១៤៣នាក់ ថយចុះ ២៩% បើធៀបនឹងខែមុន និងថយចុះ ៤.៥% ក្នុងរយៈពេល១២ខែ។

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➢យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែតុលាឆ្នាំ២០១០ មានចំនួន ១,៥៦០ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ៨.៥% ប៉ុន្តែកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ៖

| ទំនិញដែលកើនឡើង (តុលា/កញ្ញា) | ទំនិញដែលថយចុះ (តុលា/កញ្ញា) |
|---|---|
| - ប្រេងឥន្ធនៈ +១.៩%<br>- ឧស្ម័នៈ +0.៤%<br>- គ្រាក់ទ័រនិងគោយន្តៈ +១០២%<br>- ម៉ូតូៈ +២៦%<br>- ស្រូវសាលីៈ +២៧%<br>- នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ +២.៥% | - ដែកសំណង់ៈ –៣៦%<br>- ស៊ីម៉ង់ៈ –១៨%<br>- គ្រឿងអេឡិចត្រូនិចៈ –១៦%<br>- រថយន្តសរុប (ពាន់លានរៀល)ៈ –២១%<br>- ផ្លែឈើនិងបន្លែៈ –៨៣%<br>- ជីនិងថ្នាំកសិកម្មៈ –៤៨%<br>- បារីៈ –២៣% |

➢**ការនាំចេញ** ក្នុងខែតុលាឆ្នាំ២០១០ មានចំនួន ១,៥៣៣ពាន់លានរៀល កើនឡើង ១៦% ធៀបនឹងខែមុន និង កើនឡើង៣៥% ក្នុងរយៈពេល១២ខែ។ ក្នុងនោះការនាំចេញដែលកើនឡើងមាន ផលិតផលឈើកែច្នៃ ២០៧៩% ផលិតផលវាយនភណ្ឌនិងស្បែកជើង ១៦% អង្ករ ១.៧% និងផលិតផលនេសាទ ១៥៩%។
ការនាំចេញដែលថយចុះមាន កៅស៊ូ ២៦%។

➢ *ក្នុងខែតុលាឆ្នាំ២០១០នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ២៧ពាន់លានរៀល។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. បញ្ហាសំខាន់ៗ នៃស្មារតីអង្គប្រជុំ

*ក្នុងការពិភាក្សាដ៏ផុលផុសនៃកិច្ចប្រជុំនាខែនេះ ពុំមានលេចឡើងនូវបញ្ហាគួរឲ្យចាប់អារម្មណ៍ថ្មី ដើម្បីជាការកត់សម្គាល់នោះទេ។*

### ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែតុលា ឆ្នាំ២០១០នេះ សូចនាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | ក្នុងរយៈពេល១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១. ថ្លៃប្រេងសាំង | +២.៤% | +១៥% | – |
| ២. ថ្លៃប្រេងម៉ាស៊ូត | +៣.២% | +១៧% | – |
| ៣. បំណុលមូលធន | +៦៦២% | +១០៥% | – |
| ៤. ពន្ធលើប្រាក់ចំណេញ | –២៦% | –២០% | – |
| ៥. ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុង | –៦៩% | –៩២% | – |
| ៨.សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ម$^2$) | –៧៥% | –៧១% | មានការថយចុះនូវសំណង់គ្រប់ប្រភេទ ជាពិសេស សំណង់សាធារណៈ ឧស្សាហកម្ម និងទេសចរណ៍ |
| ៩. នាំចូលត្រាក់ទ័រ និងគោយន្ត | +១០២% | +៤៩៣% | – |
| ១០. នាំចេញផលិតផលឈើកែច្នៃ | +២០៧៩% | +២៥២៥% | – |

**កំណត់សំគាល់**

- ព័ត៌មាន និងទិន្នន័យពណ៌ បៃតង សំដៅលទ្ធផលល្អ
- ព័ត៌មាន និងទិន្នន័យពណ៌ ក្រហម សំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំវិច្ឆិកា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១ | ០២/១១/១០ ល្ងាច | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាង ៖<br>១- ផែនការយុទ្ធសាស្ត្រជាតិ សកម្មភាពមីន ឆ្នាំ២០១០-២០១៩<br>២- ផែនការសកម្មភាពជាតិ ស្តីពីជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប(២០១០-២០១៩)<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០៩/១១/១០ ព្រឹក ពិធីដុតទៀនជ័យ | ចូលរួមជាកិត្តិយសក្នុងពិធី ខួបអនុស្សាវរីយ៍លើកទី ៥៧ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ ។ |
| ៣ | ១០/១១/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិត ថ្នាក់បរិញ្ញាបត្ររង ជំនាន់ទី៣ ទី៤ ទី៥ ទី៦ និងទី៧ បរិញ្ញាបត្រជំនាន់ទី៣ ទី៤ ទី៥ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៤ និងទី៥ នៃសាកលវិទ្យាល័យ បៀលប្រាយ សាខាខេត្តសៀមរាប ក្រោយអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាកលវិទ្យាល័យ បៀលប្រាយ សាខាខេត្តសៀមរាប ។ |
| ៤ | ១០/១០/១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀង រៀបចំឡើងដោយ RCH International ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីធ្លាប្រាសាទបាយ័ន ខេត្តសៀមរាប ។ |
| ៥ | ១១/១១/១០ ម៉ោង ១៦:០០ ល្ងាច ពិធីពន្លត់ទៀនជ័យ | ចូលរួមជាកិត្តិយសក្នុងពិធី ខួបអនុស្សាវរីយ៍លើកទី ៥៧ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅវិមានឯករាជ្យ ។ |
| ៦ | ១១/១១/១០ ម៉ោង ១៨:០០ យប់ | ជួបប្រជុំពិភាក្សាការងារជាមួយ Mr. Nicolas Deviller និង Mr. Gardère អំពីអាទីហ្សង់អង្គរ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១២/១១/១០ ព្រឹក | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។<br>២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ។<br>៣- សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត ។<br>៤- បញ្ហាផ្សេងៗ: សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ "កិច្ចព្រមព្រៀងចំនួន០៣ក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា" ។ |
| ៨ | ១៥/១១/១០ ព្រឹក | ចូលរួមប្រជុំពិភាក្សាជាមួយ ឯកឧត្តម **ប៉ាល់ ច័ន្ទដារ៉ា** មេធាវីរាជរដ្ឋាភិបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៩ | ១៦/១១/១០ ល្ងាច ម៉ោង ១៤:២០ | ចូលរួមជាកិត្តិយសក្នុងពិធី បើកកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី ៥ (Opening Session of the 5th CLMV Summit) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅអគារសន្តិភាពនៃគណៈរដ្ឋមន្ត្រី ។ |
| ១០ | ១៧/១១/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធី បើកកិច្ចប្រជុំកំពូលយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី ចៅប្រាយ៉ា មេគង្គ លើកទី ៤ (Opening Session of the 4th ACMECS Summit) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅអគារសន្តិភាពនៃគណៈរដ្ឋមន្ត្រី ។ |
| ១១ | ១៨/១១/១០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយក្រុមកីឡាករប្រណាំងទូក "ង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ។ |
| ១២ | ១៨/១១/១០ ល្ងាច ម៉ោង ១៥:០០ - ១៧:០០ | ដឹកនាំកិច្ចប្រជុំ ពិភាក្សាលើការងារសាងសង់មជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរណ៍ (Welcome Center) ខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៣ | ១៨/១១/១០ ល្ងាច ម៉ោង ១៧:០០ - ១៨:០០ | ប្រជុំជាមួយក្រុមហ៊ុនសាងសង់វិស្វកម្មយូណាន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៩/១១/១០ ព្រឹក - ល្ងាច | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើ ÷<br>១- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១១-២០១៣<br>២-១. សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ<br>២-២. សេចក្តីព្រាងអនុក្រឹត្យស្តីពីរូបសញ្ញា និងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ<br>២-៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងនិងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុកលួយ<br>៣- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | ២៥/១១/១០<br>ពេញមួយថ្ងៃ | ចូលរួមក្នុងសម័យប្រជុំពេញអង្គលើកទី១៧ នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ (CIC) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅខេត្តសៀមរាប ។ |
| ១៦ | ២៦/១១/១០ ល្ងាច | ចូលរួមជាកិត្តិយសក្នុងពិធីបិទជំនួបបណ្ឌិតសភាស្តីពី "អនាគតអាស៊ានសតវត្សទី២១ : បញ្ហាប្រឈម និងទស្សនវិស័យ" និងពិធីបំពាក់គ្រឿងឥស្សរិយយស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៧ | ២៩/១១/១០<br>ម៉ោង ៧:៣០ ព្រឹក | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ទីស្តីការ និងអគាររដ្ឋបាលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅរាជធានីភ្នំពេញ ។ |
| ១៨ | ២៩/១១/១០<br>ម៉ោង ១៥:៣០ ល្ងាច | ប្រជុំជាមួយ " សិប្បករអង្គរ " ។ |
| ១៩ | ៣០/១១/១០ ព្រឹក | ដឹកនាំអង្គប្រជុំទូលាយ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម គីម សយសាម៉ាឡៃន អនុប្រធាន ECOSOCC ប្រចាំខែវិច្ឆិកា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ៨/១១/១០ | ប្រជុំត្រួតពិនិត្យជាចុងក្រោយ ស្តីពីផែនការជាតិសកម្មភាពមីនកម្ពុជា ២០១០-២០១៩។ |
| ២ | ១០/១១/១០ | ប្រជុំ ORIA Update Meeting. |
| ៣ | ១២-១៨/១១/១០ | ចូលរួមក្នុងវគ្គបណ្តុះបណ្តាល RIA ដល់មន្ត្រី ORIA ។ |
| ៤ | ២៦/១០/១០ | ចូលរួមជាកិត្តិយសក្នុងពិធីបិទជំនួបបណ្ឌិតសភាស្តីពី "អនាគតអាស៊ានទសវត្សទី២១ : បញ្ហាប្រឈម និងទស្សនវិស័យ" និងពិធីបំពាក់គ្រឿងឥស្សរិយយស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន អនុប្រធាន ECOSOCC ប្រចាំវិច្ឆិកា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៦/១១/១០ | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិត សភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ី ដឹកនាំដោយ ឯកឧត្តម Putu Kamayana តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ ស្តីពីកិច្ចសហប្រតិបត្តិការទំនាក់ទំនង និងអាជ្ញាធរជាតិប្រេងកាតកម្ពុជា និងការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តិ។ |
| ២ | ១៨/១១/១០ | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយក្រុមកីឡាករប្រណាំងទូក "ង" របស់ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិត សភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២៦/១០/១០ | ចូលរួមជាកិត្តិយសក្នុងពិធីបិទជំនួបបណ្ឌិតសភាស្តីពី "អនាគតអាស៊ានទសវត្សទី២១ : បញ្ហាប្រឈម និងទស្សនវិស័យ" និងពិធីបំពាក់គ្រឿងឥស្សរិយយស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ២៩/១១/១០ | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់អគារមជ្ឈមណ្ឌលតំកល់ឯកសារច្បាប់ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ សមាជិក-សមាជិកា
# សកម្មភាក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/១១/១០ | ឯកឧត្តម **ឌិន វីរៈ** និងឯកឧត្តម **ឡោ ប៉ូលីណា** ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពីចំណាត់ថ្នាក់ដំណាក់កាលនៃសន្តិសុខស្បៀងចម្រុះថ្នាក់ជាតិ (National Integrated Food Security Phase Classification, IPC) នៅសណ្ឋាគារភ្នំពេញ ដែលរៀបចំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ កម្មវិធីស្បៀងអាហារពិភពលោក និង អ្នកពាក់ព័ន្ធផ្សេងទៀត។ |
| ២ | ១២/១១/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែតុលា របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |







រូបភាពក្នុងកិច្ចប្រជុំ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ដំណើរទស្សនកិច្ចពិភាក្សា(Retreat)ស្តីពី

# ការរៀបចំការងារ ដើម្បីត្រៀមអនុវត្តគម្រោង វាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត

ការិយាល័យវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត(ORIA) របស់ ECOSOCC បានរៀបចំដំណើរទស្សនកិច្ចពិភាក្សា(Retreat) ស្តីពីការរៀបចំការងារដើម្បីត្រៀមអនុវត្តគម្រោងវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត(RIA) រយៈពេល២ថ្ងៃ គឺថ្ងៃទី១៥ និងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ នៅខេត្តព្រះសីហនុ។

ដំណើរទស្សនកិច្ចពិភាក្សានេះដឹកនាំដោយ ឯកឧត្តម យឹម ណុលសន អនុប្រធាន ECOSOCC និងជានាយករង ORIA និងដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ខង សំអាង** អគ្គលេខាធិការ ECOSOCC និងជាអ្នកគ្រប់គ្រង ORIA លោក Sabest Shivasabcsan អ្នកជំនាញការផ្នែកវាយតម្លៃលិខិតបទដ្ឋានគតិយុត្តរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) លោក **អ៊ូ ផាន់ណារិទ្ធ** អ្នកជំនាញប្រព័ន្ធព័ត៌មានវិទ្យា និងមន្ត្រីជំនាញទាំងអស់នៃ ORIA។

ដំណើរទស្សនកិច្ចពិភាក្សារយៈពេល២ថ្ងៃនេះ បានប្រព្រឹត្តទៅដោយមានការធ្វើបទបង្ហាញ សំណួរ-ចម្លើយ និងការធ្វើអត្ថាធិប្បាយផ្សេងៗប្រកបដោយផ្លែផ្កា ក្នុងនោះលោក Sabest Shivasabcsan បានធ្វើបទបង្ហាញ ស្តីពីទិដ្ឋភាពទូទៅនៃប្រតិបត្តិការ RIA ដែលក្នុងនេះមានប្រធានបទតូចៗចំនួន៤ គឺ

១- An outline of ORIA's functions and responsibilities

២- Working line line-ministries, key skills and challenges

៣- Overseas experience in implementing RIA

៤- ORIA's challenges in implementing RIA throughout RGC

ឯកឧត្តម **ខង សំអាង** បានធ្វើបទបង្ហាញស្តីពីការវិវត្តរបស់ ORIA មកដល់ពេលបច្ចុប្បន្ន និងកំណត់ទិសដៅទៅថ្ងៃមុខ និងដឹកនាំកិច្ចពិភាក្សាកែលម្អលើឯកសារចំនួន៣ គឺ PA template Ckecklist និង RIA guidelines។

លោក **អ៊ូ ផាន់ណារិទ្ធ** បានធ្វើបទបង្ហាញស្តីពីការរៀបចំគេហទំព័ររបស់ ECOSOCC ( ECOSOCC's Website) ដែលនឹងត្រូវបង្ហោះនៅពេលឆាប់ៗខាងមុខនេះ។

ដំណើរទស្សនកិច្ចពិភាក្សាបានបញ្ចប់ដោយជោគជ័យ៕

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម គឹម ស៊ីម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម ម៉ុង ស៊ីផេង | អគ្គលេខាធិការ ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម អ៊ឹម សារ៉ុន | សមាជិកបម្រុង ក.ស.វ. |
| និពន្ធអក្ខរាវិរុទ្ធ ៖ | ឯកឧត្តម ថេង ផ្លូវភិនី | អគ្គលេខាធិការរង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក ស៊ុយ វណ្ណ | ប្រធានការិយាល័យ ក.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក ទេង សុភ័ក្ត្រ | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក អ៊ុក ឯតា | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in